# ប្រដាប់ប្រដាសំរាប់ពហុគ្រួសារ

សូមអរគុណ ចំពោះការចូលរួម ក្នុងកម្មវិធីច្នៃប្រើទៀតរបស់ក្រុង Tacoma! ធ្វើឲ្យកម្មវិធីច្នៃប្រើទៀតរបស់អ្នកបានជោគជ័យ ដោយធ្វើតាមជំហានទាំង 3 នេះ៖

## ជំហានទី 1៖ រៀបចំកម្មវិធីច្នៃប្រើទៀតរបស់អ្នក


បញ្ជីពិនិត្យ កម្មវិធីច្នៃប្រើទៀត . . . . . . . . . . 2

របៀបដាក់ធុងច្នៃប្រើទៀត របស់អ្នកនៅក្រៅ . . . . . . . . . . 3

ធនធានរបស់ Solid Waste សំរាប់អ្នកចាត់ចែងភូមិគ្រឹះ . . . . . . . . . . 4


## ជំហានទី 2៖ ជំរាបអ្នកស្រុករបស់អ្នក


សំបុត្រស្វាគមន៍អ្នកស្រុកថ្មី. . . . . . . . . . 5

សំបុត្រកម្មវិធីថ្មី នៃការច្នៃប្រើទៀត. . . . . . . . . . 6

របៀប ច្នៃប្រើទៀតត្រឹមត្រូវ. . . . . . . . . . 7

វត្ថុ 8 មុខ ដែលមិនត្រូវនៅក្នុងធុងច្នៃប្រើទៀត. . . . . . . . . . 8

មគ្គុទ្ទេសក៍ការផ្លាស់លំនៅ . . . . . . . . . . 9

វត្ថុ 8 មុខ ដែលអាចទំលាក់ចោល នៅ Tacoma Recovery & Transfer Center . . . . . . . . . 10

ធនធានរបស់ Solid Waste សំរាប់អ្នកស្រុក . . . . . . . . . . 11


## ជំហានទី 3៖ រក្សាកម្មវិធីច្នៃប្រើទៀត របស់អ្នកដោយជោគជ័យ

រំលឹក និងញុំាងចិត្តអ្នកស្រុក ចំពោះ ច្នៃប្រើទៀតត្រឹមត្រូវ ដោយមាន បដា, ខិត្តប័ណ្ណ, មេដែក, និងធនធានបន្ថែម។ សំភារៈទាំងអស់ គឺមានសំរាប់ទាញយក នៅ *tacomarecycles.org*។ សំរាប់**ធនធានដែលបានផ្ដិត** ទាក់ទង Tacoma Recycles លេខ (253) 502-2100។

▶ បដាការច្នៃប្រើទៀត




▶ ខិត្តប័ណ្ណ




▶ មេដែកព្យួរនៅទ្វារ




▶ ថង់យួរ



# បញ្ជីពិនិត្យ កម្មវិធីច្នៃប្រើទៀត

បំពេញបញ្ជីពិនិត្យនេះ ដើម្បីឲ្យដឹងបើសិនអ្នកបានប្រុងប្រៀប រៀបចំកម្មវិធីច្នៃប្រើទៀត ដោយជោគជ័យ!

**ឱវាទល្អ** ជៀសវាងថ្លៃឈ្នួល និងបានខាតមកប្រមូលយក មកពីការបោះចោលខុសច្បាប់ ដោយពិនិត្យឡើងវិញ នូវកម្មវិធីច្នៃប្រើទៀតរបស់អ្នក *រៀង*រាល់ឆ្នាំ។

## តើវាងាយស្រួល ដើម្បីច្នៃប្រើទៀត នៅក្នុងអាគាររបស់ខ្ញុំ ឬទេ?

| | បាទ/ចាស | ទេ |
|---|---|---|
| ធុងច្នៃប្រើទៀតទាំងអស់ គឺបានដាក់ស្លាកយ៉ាងច្បាស់ ដោយមានអ្វីដែលអាចច្នៃប្រើទៀត | ☐ | ☐ |
| មានព័ត៌មានស្ដីពីរបៀប ច្នៃប្រើទៀតត្រឹមត្រូវ នៅក្បែរធុងច្នៃប្រើទៀត | ☐ | ☐ |
| អ្នកស្រុកទាំងអស់ បានទទួលព័ត៌មាន ច្នៃប្រើទៀតត្រឹមត្រូវ ទាន់បច្ចុប្បន្នភាព ក្នុងពេល 12 ខែកន្លងមក | ☐ | ☐ |
| មានសំបុត្រសារព័ត៌មាន និងកិច្ចប្រជុំ រំលឹកស្ដីពីរបៀប ច្នៃប្រើទៀតត្រឹមត្រូវ នៅក្នុងសហគមន៍ | ☐ | ☐ |

បើសិនអ្នកបានឆ្លើយ "**ទេ**" ចំពោះសេចក្ដីថ្លែងណាមួយខាងលើ ទស្សនា *tacomarecycles.org* ដើម្បីទាញយក ខិត្តប័ណ្ណច្នៃប្រើទៀត ឬទាក់ទង Solid Waste សំរាប់ស្លាកថ្មី។

## តើខ្ញុំកំពុងតែធ្វើអ្វីៗ ដែលខ្ញុំអាចធ្វើ ដើម្បីការពារ ការបោះចោលខុសច្បាប់ ឬទេ?

| | បាទ/ចាស | ទេ |
|---|---|---|
| មានធុងច្នៃប្រើទៀតមួយ នៅក្បែររាល់ធុងសំរាម | ☐ | ☐ |
| កន្លែងចោលសំណល់ គឺស្អាត និងបានរក្សាយ៉ាងល្អ ហើយធុងគឺមិនខូច ឬត្រូវបានបំផ្លិចបំផ្លាញ | ☐ | ☐ |
| វត្ថុសំពីងសំពោង, សំរាម, ឬសំភារៈដែលគ្រោះថ្នាក់ គឺមិនបានទុកនៅលើដី ឬក្នុងធុងច្នៃប្រើទៀត | ☐ | ☐ |

បើសិនអ្នកបានឆ្លើយ "**ទេ**" ចំពោះសេចក្ដីថ្លែងណាមួយខាងលើ ទាក់ទង Solid Waste ដើម្បីស្វែងយល់ របៀបអ្នកអាចការពារ ការបោះចោលខុសច្បាប់ ឬដូរធុងដែលខូច។

## តើខ្ញុំត្រូវធ្វើការកែសំរួល ចំពោះសេវាច្នៃប្រើទៀត/សំរាម ឬទេ?

| | បាទ/ចាស | ទេ |
|---|---|---|
| មានវត្ថុអាចច្នៃប្រើទៀត (ដូចជា៖ ក្រដាសក្រាស់ៗ, ដបទឹក) ក្នុងធុងសំរាម | ☐ | ☐ |
| មានសំរាម (ដូចជា៖ ម្ហូបចំណី, ខោអាវ, វត្ថុមិនអាចច្នៃប្រើទៀត) នៅក្នុងធុងច្នៃប្រើទៀត | ☐ | ☐ |
| ធុងច្នៃប្រើទៀត គឺពេញ មុនវាត្រូវបានមកដឹក | ☐ | ☐ |
| ធុងច្នៃប្រើទៀត គឺតិចជាង 75% ពេញ មុនវាត្រូវបានមកដឹក | ☐ | ☐ |

បើសិនអ្នកបានឆ្លើយ "**បាទ/ចាស**" ចំពោះសេចក្ដីថ្លែងណាមួយខាងលើ ទាក់ទង Solid Waste ដើម្បីប្ដូរកម្រិតនៃសេវារបស់អ្នក។

សំរាប់ព័ត៌មានថែមទៀត ទាក់ទង៖

City of Tacoma Solid Waste
(253) 502-2100
solidwaste@cityoftacoma.org
cityoftacoma.org/solidwaste

ដើម្បីគ្រោងពេលមកដឹក វត្ថុសំពីងសំពោងធំៗ ដោយមានថ្លៃឈ្នួលតិច ទាក់ទង៖

Call-2-Haul
(253) 573-2468
cityoftacoma.org/call2haul

# របៀបដាក់ធុងច្នៃប្រើទៀត របស់អ្នកនៅក្រៅ

**ជៀសវៀងថ្លៃឈ្នួលបន្ថែម** មកពីការបោះចោលខុសច្បាប់ និងបានខានមកប្រមូលយក ដោយធ្វើតាមជំហានខាងក្រោម ទាំងនេះ៖

**1** **យកសំរាមចេញ** ពីធុងច្នៃប្រើទៀត។




**2** **កុំឲ្យធុងច្នៃប្រើទៀត** ពេញពេក។




**3** **ដាក់ធុងច្នៃប្រើទៀត ឲ្យទាន់ម៉ោង 6 ព្រឹក** នៅថ្ងៃមកដឹក របស់អ្នក។

**4** **លំហគឺសំខាន់។** ដាក់ធុងដែលមានកង់ លើចិញ្ចើមថ្នល់ និងឃ្លាតគ្នាយ៉ាងហោច 4 ហ្វីត និងឆ្ងាយពីអ្វីៗដែលទើសក្បាល (ដូចជា មែកឈើ, បង្គោលទូរស័ព្ទ) និងវត្ថុផ្សេងៗទៀត។







**5** **យកធុងច្នៃប្រើទៀត ចេញពីចិញ្ចើមថ្នល់** កាលណាវានៅទទេ។

**6** **ដាក់ធុងច្នៃប្រើទៀត ក្នុងកន្លែងបិតថេរ** ដែលមានតែអ្នកស្រុករបស់អ្នក អាចប្រើបាន។

ហៅអ្នកតំណាង **Solid Waste** លេខ **(253) 502-2100** បើសិនធុងច្នៃប្រើទៀតរបស់អ្នក មិនបានមកដឹក ឬបើសិនអ្នកមានសំណួរ អំពីគោលការណ៍ណែនាំ ដាក់នៅក្រៅ។

# ធនធានរបស់ SOLID WASTE សំរាប់អ្នកចាត់ចែងភូមិគ្រឹះ

**Solid Waste Management**
3510 S. Mullen St.
(253) 502-2100
cityoftacoma.org/solidwaste
solidwaste@cityoftacoma.org

Solid Waste ផ្តល់ជូនសេវាយកសំរាម, វត្ថុច្នៃប្រើទៀត និងម្ហូបចំណី/សំណល់ទីធ្លាព្រមទាំង ជំរើសដឹកខ្លួនឯង សំរាប់សំរាម, វត្ថុច្នៃប្រើទៀត, សំណល់ទីធ្លា និង សំណល់នៃវត្ថុប្រើក្នុងផ្ទះ ដែលគ្រោះថ្នាក់ នៅ Tacoma Recovery & Transfer Center។

**Call-2-Haul**
(253) 573-2468
cityoftacoma.org/call2haul

គ្រោងពេលមកដឹក នូវវត្ថុសំពីងសំពោង។ វត្ថុធំៗដល់ទៅ 3 និង 15 ប្រអប់ ឬថង់នៃសំរាមវត្ថុតូចៗ អាចបានមកដឹក។ ថ្លៃឈ្នួលមកដឹកគឺ $75 និងបានបន្ថែមទៅគណនីទឹកភ្លើងរបស់អ្នក។ ទស្សនាគេហទំព័រ សំរាប់បញ្ជីនៃវត្ថុអាចយកបាន។

**FoodCycling**
(253) 502-2100
cityoftacoma.org/foodcycling

បង្វែរសំណល់ម្ហូបចំណីរបស់អ្នកស្រុក ទៅជាជីអំពុក ដោយបន្ថែមសេវា FoodCycling របស់យើង។ វាងាយស្រួលដើម្បីរៀបចំ!

**Waste Free 253**
wastefree253.org

ការផ្លាស់លំនៅ អាចបង្កើតឲ្យមានសំណល់ច្រើន។ Waste Free 253 មានឱវាទស្តីពីរបៀបកាត់បន្ថយសំណល់ និងកន្លែងដើម្បីធ្វើអំណោយវត្ថុប្រើក្នុងផ្ទះ។

**Recycle Center**
3510 S. Mullen St.
(253) 593-7795
tacomarecycles.org

អ្នកស្រុកអាចទំលាក់ចោល នូវវត្ថុអាចច្នៃប្រើទៀតទាំងអស់ ដោយឥតគិតថ្លៃ រួមទាំងអ្វីៗដែលមិនអាចយក នៅចិញ្ចើមថ្នល់ (ថង់ជ័រ និងប្រដាប់រុំ, ប្រអប់ខ្ចប់ម្ហូបជ័រ, ស្តៃរ៉ូហ្វូម, ខ្សែអគ្គិសនី, ល.) នៅឯ Recycle Center។ Recycle Center គឺបើកប្រាំពីរថ្ងៃមួយអាទិត្យ ម៉ោង 8 ព្រឹក–6 ល្ងាច។ ទស្សនាគេហទំព័រ សំរាប់សេចក្តីពិស្តារថែមទៀត។

**Household Hazardous Waste**
3510 S. Mullen St.
(253) 591-5418
cityoftacoma.org/hazwaste

អ្នកស្រុក **អាចចោលសំណល់ប្រើក្នុងផ្ទះដែលគ្រោះថ្នាក់** (ថ្មពិល, អំពូលភ្លើង, គ្រឿងជូតសំអាតផ្ទះ, ល.) **ដោយឥតគិតថ្លៃ** នៅឯ Household Hazardous Waste Center។ ទស្សនាគេហទំព័រ សំរាប់បញ្ជីនៃវត្ថុអាចយកបាន។

**EnviroHouse**
ការិយាល័យ៖ (253) 573-2426
ចល័ត៖ (253) 341-2331
ehouse@cityoftacoma.org
cityoftacoma.org/envirohouse

អ្នកស្រុករបស់អ្នក អាចទទួល **សិក្ខាពិភាក្សាតាមបណ្តាញ ឥតគិតថ្លៃ ស្តីពីការធ្វើច្បារ, ការសំអាត, និងការរស់នៅ អាចរក្សាបាន** នៅឯ EnviroHouse—ការបង្ហាញផ្ទះគំរូមួយ នៃអាគារខៀវ និងគំនិតទេសភាពធម្មជាតិ, សំភារៈ, និងបច្ចេកទេស ដើម្បីបង្កើតផ្ទះ និងពិភព មួយមានសុខភាពល្អ។ ចូលរួមសិក្ខាពិភាក្សា រស់រវើកតាមបណ្តាញ ឬមើលការថតពីមុនៗ នៅឯគេហទំព័រ។

**3-1-1**
ហៅ 3-1-1 (ក្នុងកម្រិតក្រុង)
ឬ (253) 591-5000
cityoftacoma.org/tacomafirst311

បុគ្គលិកក្រុង Tacoma ធ្វើការពីម៉ោង 8 ព្រឹក–5 ល្ងាច ថ្ងៃច័ន្ទ–ថ្ងៃសុក្រ ដើម្បី ឆ្លើយសំណួរទូទៅ **អំពីរដ្ឋាភិបាល និងសេវា** នៃក្រុង Tacoma។

**តើអ្នកបានដឹងឬទេ?**

**អ្នកអាចស្នើសុំសោ សំរាប់ធុងរបស់អ្នក។** ចាក់សោជួយការពារ ការបោះចោលខុសច្បាប់! ទាក់ទង Solid Waste ដើម្បីស្នើសុំសោ សំរាប់ភូមិគ្រឹះរបស់អ្នក។

# ស្វាគមន៍មកផ្ទះថ្មីរបស់អ្នក!

សូមជូនមកដល់អ្នកស្រុកថ្មី,

យើងមានមោទនភាព ក្នុងការបង្កើតបរិស្ថានមួយ ដែលស្អាត និងមានសុខភាពល្អ។ អ្នកអាចជួយបានដោយ ច្នៃប្រើទៀតត្រឹមត្រូវ!

**តើហេតុអ្វីវាសំខាន់ ចំពោះ ច្នៃប្រើទៀតត្រឹមត្រូវ?** ច្នៃប្រើទៀតត្រឹមត្រូវ ជួយការពារបរិស្ថាន តាមរយៈការ៖

- សំចៃធនធានធម្មជាតិរបស់យើង,
- កាត់បន្ថយសំណល់ ពីការចោលនៅដីគំនរសំរាមរបស់យើង,
- គាំទ្របរិស្ថានមួយមានសុខភាពល្អ សំរាប់មនុស្សជំនាន់ក្រោយ, និង
- រក្សាអ្នកធ្វើការច្នៃប្រើទៀត បានសុខសប្បាយ។




**តើខ្ញុំច្នៃប្រើទៀតត្រឹមត្រូវ ដូចម្តេច?** ធ្វើឲ្យប្រាកដ ថាការប្រឹងប្រែងរបស់អ្នក មិនបានខាតបង់ ដោយនឹកចាំវិន័យដ៏សាមញ្ញទាំងនេះ៖

- **ស្គាល់វត្ថុអ្វីខ្លះ ដែលអាចច្នៃប្រើទៀត។** ទស្សនា *tacomarecycles.org* ដើម្បីស្វែងយល់ថែមទៀត។
- វត្ថុអាចច្នៃប្រើទៀត ត្រូវជា **ទទេ ជ្រះ និងស្ងួត** មុននឹងដាក់វាទៅក្នុងធុង។
- **កុំដាក់វត្ថុអាចច្នៃប្រើទៀត ក្នុងថង់!** ដាក់វត្ថុអាចច្នៃប្រើទៀត រាត់រាយ ទៅក្នុងធុង។
- **កុំឲ្យពេញធុងពេក។** ធុងដែលពេញពេក មិនលើកយកទេ។ យកវត្ថុអាចច្នៃប្រើទៀត របស់អ្នកទៅ Tacoma Recycle Center។




| | | |
|---|---|---|
| **ទទេ** | **ជ្រះ** | **ស្ងួត** |
| ចាក់ទឹកចេញ និង កោសម្ហូបចេញ។ | លាងប្រដាប់ដាក់ ឲ្យសព្វ។ | រលាក់ទឹកនៅសល់ ឲ្យអស់ និងស្ងួត។ |

**ឱកាសល្អ**

♻ **សញ្ញានេះ មិនតែងតែបង្ហាញ ថាវត្ថុមួយអាចច្នៃប្រើទៀត** នៅក្នុង Tacoma ឡើយ។
ផ្ទៃកបញ្ជាក់ បើសិនវត្ថុមួយអាចច្នៃប្រើទៀត នៅ *tacomarecycles.org* ឬហៅ (253) 502-2100។

# ការច្នៃប្រើទៀត គឺមានហើយឥឡូវនេះ!

សូមជូនមកដល់អ្នកស្រុក,

យើងមានសេចក្តីរីករាយ ដើម្បីប្រកាសអំពីកម្មវិធីថ្មីរបស់យើង នៃការច្នៃប្រើទៀតទូទាំងអាគារ។ យើងមានមោទនភាព ក្នុងការបង្កើតបរិស្ថានមួយ ដែលស្អាត និងមានសុខភាពល្អ សំរាប់អាគារ និងសហគមន៍របស់យើង។ យើងត្រូវការជំនួយពីអ្នក ដើម្បីធ្វើឲ្យកម្មវិធីនេះបានចាប់ផ្តើមល្អ!

**តើហេតុអ្វីវាសំខាន់ ចំពោះ ច្នៃប្រើទៀតត្រឹមត្រូវ?** ច្នៃប្រើទៀតត្រឹមត្រូវ ជួយការពារបរិស្ថាន តាមរយៈការ៖

- សំចៃធនធានធម្មជាតិរបស់យើង,
- កាត់បន្ថយសំណល់ ពីការចោលនៅដីគំនរសំរាមរបស់យើង,
- គាំទ្របរិស្ថានមួយមានសុខភាពល្អ សំរាប់មនុស្សជំនាន់ក្រោយ, និង
- រក្សាអ្នកធ្វើការច្នៃប្រើទៀត បានសុខសប្បាយ។




**តើខ្ញុំធ្វើ ច្នៃប្រើទៀតត្រឹមត្រូវ ដូចម្តេច?** ធ្វើឲ្យប្រាកដ ថាការប្រឹងប្រែងរបស់អ្នក មិនបានខាតបង់ ដោយនឹកចាំវិន័យដ៏សាមញ្ញទាំងនេះ៖

- **ស្គាល់វត្ថុអ្វីខ្លះ ដែលអាចច្នៃប្រើទៀត។** ទស្សនា *tacomarecycles.org* ដើម្បីស្វែងយល់ថែមទៀត។
- វត្ថុអាចច្នៃប្រើទៀត ត្រូវជា **ទទេ ជ្រះ និងស្ងួត** មុននឹងដាក់វាទៅក្នុងធុង។
- **កុំដាក់វត្ថុអាចច្នៃប្រើទៀត ក្នុងថង់!** ដាក់វត្ថុអាចច្នៃប្រើទៀត រាត់រាយ ទៅក្នុងធុង។
- **កុំឲ្យពេញធុងពេក។** ធុងដែលពេញពេក មិនលើកយកទេ។ យកវត្ថុអាចច្នៃប្រើទៀត របស់អ្នកទៅ Tacoma Recycle Center។




| ទទេ | ជ្រះ | ស្ងួត |
|---|---|---|
| ចាក់ទឹកចេញ និង កោសម្ហូបចេញ។ | លាងប្រដាប់ដាក់ ឲ្យសព្វ។ | រលាក់ទឹកនៅសល់ ឲ្យអស់ និងស្ងួត។ |

**ឱកាទល្អ** ✓

♻ **សញ្ញានេះ** **មិន****តែងតែបង្ហាញ ថាវត្ថុមួយមុខ អាចច្នៃប្រើទៀត** នៅក្នុង Tacoma ឡើយ។ ឆែកបញ្ជាក់ បើសិនវត្ថុមួយអាចច្នៃប្រើទៀត នៅ *tacomarecycles.org* ឬហៅ (253) 502-2100។

# របៀប ច្នៃប្រើទៀតត្រឹមត្រូវ

**តើអ្នកបានដឹងឬទេ?** ?

ថង់ជ័រធ្វើឲ្យគាំងឧបករណ៍បំបែក និងអាចបណ្តាលឲ្យស្លាប័ន ច្នៃប្រើទៀត ទាំងមូល បិទចោល។ ចូរ**កុំ**ដាក់វត្ថុច្នៃប្រើទៀត ក្នុងថង់ជ័រ! ប្រើថង់អាចប្រើទៀត ឬធុង ដើម្បីយកចេញទៅក្រៅ និងចាក់វាចេញ ចូលទៅក្នុងធុង។




## ការច្នៃប្រើទៀត

អំពូលភ្លើង**ជ័រ**, ដប និងក្រឡ, **ក្រដាស** និងក្រដាសក្រាស់ៗ, កំប៉ុង**ដែក** (គ្មានគំរប)






## សំរាម

ចង់ជ័រ និងប្រដាប់រុំ, ស្នៃរ៉ូហ្វូម, ពេង និងចាន ក្រដាស, ប្រដាប់ដាក់ម្ហូបមានខ្លាញ់, ប្រអប់ក្រដាស, ក្រដាសអាលុយមីណូម






**តើហេតុអ្វី ត្រូវជា ទទេ ជ្រះ និងស្ងួត?** វត្ថុអាចច្នៃប្រើទៀត គួរតែបានចាក់ចេញ ស្អាត និងស្ងួត ដើម្បីការពារកុំឲ្យប្រទ្បាក់វត្ថុអាចច្នៃប្រើទៀត ដទៃទៀត។ វត្ថុអាចច្នៃប្រើទៀតដែលប្រឡាក់ ត្រូវបានបញ្ជូនទាំងអស់ ទៅដីគំនរសំរាម!

#tacomarecycles | facebook.com/TacomaES | tacomarecycles.org

Tacoma SURFACEWATER SOLIDWASTE WASTEWATER ENVIRONMENTAL SERVICES DEPARTMENT

# វត្ថុ ៩ មុខ ដែល**មិន**ត្រូវនៅក្នុងធុងច្នៃប្រើទៀត

**តើអ្នកបានដឹងឬទេ?**

វត្ថុច្នៃប្រើទៀតទាំងអស់ ត្រូវតែបានគ្រវាត់ចោល បើសិនវាមានសំរាម គ្រាន់តែបន្តិចបន្តួច ឬមានវត្ថុកខ្វក់។ រកមើលវា ឬទុកវាឲ្យនៅក្រៅធុងច្នៃប្រើទៀត!

វត្ថុទាំងនេះ ជាញឹកញយបានដាក់ក្នុងធុងច្នៃប្រើទៀត ដោយច្រឡំ។ ស្វែងយល់ពីរបៀប បោះវាចោលដោយត្រឹមត្រូវ!

## សំរាម

គ្រវាត់ចោល ក្នុងធុងសំរាម។

### ប្រអប់ក្រដាស និងប្រដាប់ដាក់ម្ហូបកក




ប្រអប់ក្រដាស មានស្រទាប់, ដែក, និងជ័រ ដើម្បីដាក់ទឹក។ ប្រអប់ម្ហូបកកដែលមានជ័រ ដើម្បីការពារម្ហូបពីការកកខ្លាំងពេក។ ស្ថាប័នរបស់យើង មិនអាចបំបែកស្រទាប់ទាំងនេះទេ។

### ពែងកាហ្វេ



ពែងកាហ្វេក្រដាស គឺត្រូវគ្នាជាមួយជ័រ។ ស្ថាប័នរបស់យើង ពុំមានបច្ចេកវិជ្ជា ដើម្បីបំបែករបស់ស្រទាប់ៗ ទាំងនេះទេ។

### ប្រអប់នំពីស្សា



ប្រអប់នំពីស្សា គឺប្រឡាក់ដោយឈីស្ស, ទឹកគ្រឿង, និងប្រេង។ តែក្រដាសក្រាស់ៗជ្រះ អាចច្នៃប្រើទៀត។

## ទំលាក់ចោល

នៅ Household Hazardous Waste នៅ 3510 S. Mullen St.

❌ ថ្មពិល **មិន**អាចបានចោលក្នុងសំរាមទេ។

### ថ្មពិល




ថ្មពិល គឺជាសំណល់ដែលគ្រោះថ្នាក់មានជាតិពុល ដែលអាចប្រឡាក់ដល់ដី និងទឹក បើបានចោលមិនត្រឹមត្រូវ។

## ទំលាក់ចោល

នៅ Recycle Center នៅ នៅ 3510 S. Mullen St.*

*វត្ថុទាំងនេះអាច **គ្រវាត់ចោល** ឬ **បានច្នៃប្រើទៀត** នៅឯ Recycle Center។

### ថង់ជ័រ និងប្រដាប់រុំ




ថង់ជ័រ អាចជាប់ និងគាំង ក្នុងម៉ាស៊ីនបំបែកវត្ថុច្នៃប្រើទៀត ធ្វើឲ្យដំណើរការច្នៃប្រើទៀតទាំងអស់ឈប់ដើរ។

### ប្រអប់ស្នូកលៀសជ័រ



ប្រអប់ស្នូកលៀសជ័រ អាចធ្វើឲ្យសំប៉ែតយ៉ាងងាយ ដែលធ្វើឲ្យពិបាកសំរាប់ម៉ាស៊ីន ដើម្បីបំបែកវាបានត្រឹមត្រូវ។

### ស្តៃរ៉ូហ្វូម



ដុំកញ្ចប់ស្តៃរ៉ូហ្វូម និងសណ្តែកដីងាយបែក បង្កើតជាពង្រាយ និងធ្វើឲ្យវាពិបាក សំរាប់ម៉ាស៊ីនដើម្បីបំបែកបានត្រឹមត្រូវ។

### ខ្សែអគ្គិសនី



ខ្សែភ្លើង, ខ្សែអំពូលភ្លើង, ខ្សែបញ្ចូលភ្លើង ធ្វើឲ្យវណ្ឌ និងជាប់ ម៉ាស៊ីនបំបែក។

# មគ្គុទ្ទេសក៍ផ្លាស់លំនៅ ច្នៃប្រើទៀតត្រឹមត្រូវ

ការផ្លាស់លំនៅ អាចបង្កើតឲ្យមានសំណល់ច្រើន។ ការចោលវត្ថុដែលមិនចង់បាន តាមរបៀបត្រឹមត្រូវ ដោយធ្វើតាមជំហានទាំងនេះ។

1




## លក់ ឬធ្វើអំណោយ វត្ថុដែលនៅល្អ។

ទស្សនា *cityoftacoma.org/wastefree253* សំរាប់បញ្ជីនៃកន្លែងដើម្បីលក់ ឬធ្វើអំណោយវត្ថុរបស់អ្នក។

2




## ទស្សនា Tacoma Recovery & Transfer Center នៅ 3510 S. Mullen St.

ទំលាក់ចោលវត្ថុ ដែលមិនអាចលក់ ឬធ្វើអំណោយបាន រួមទាំង សំលៀកបំពាក់, គ្រឿងប្រើប្រាស់តូចៗ, ប្រអប់ឬសំភារះខ្ចប់, វត្ថុសំពីងសំពោងធំៗ, សំណល់ប្រើក្នុងផ្ទះ ដែលគ្រោះថ្នាក់។ ទស្សនា *cityoftacoma.org/solidwaste* ឬហៅ 253-502-2100 សំរាប់ព័ត៏មានថែមទៀត។

3

## ទំលាក់ចោល សំណល់គ្រឿងអេឡិត្រូនិក នៅកន្លែង E-cycle មួយ។

ទស្សនា *RecycleWashington.org* ឬហៅ 1-800-RECYCLE សំរាប់បញ្ជីនៃវត្ថុអាចចោលបាន និងដើម្បីរកកន្លែង E-cycle មួយនៅជិតអ្នក។ ចូរកុំបោះចោល សំណល់អេឡិកត្រូនិក ក្នុងធុងសំរាម ឬធុងច្នៃប្រើទៀត។



4




## គ្រោងពេលមកដឹក ជាមួយ Call-2-Haul។

វត្ថុធំៗដល់ទៅ 3 និង 15 ប្រអប់ ឬថង់ នៃសំរាមវត្ថុតូចៗ អាចបាន មកដឹក។ ទស្សនា *cityoftacoma.org/call2haul* សំរាប់បញ្ជីនៃវត្ថុអាចយកបាន និងថ្លៃឈ្នួល ឬហៅ (253) 573-2468។

បើកក្រទ្បាប់ទំព័រ ដើម្បីឲ្យដឹងរបៀប កំចាត់ចោលវត្ថុទូទៅប្រើក្នុងផ្ទះ នៅពេលផ្លាស់លំនៅ។

# វត្ថុ 8 មុខ ដែលអាចទំលាក់ចោល នៅ TACOMA RECOVERY & TRANSFER CENTER

ការផ្លាស់លំនៅ ឬការកំចាត់ចោលរបស់របរ? Tacoma Recovery & Transfer Center នៅ 3510 S. Mullen St. គឺជាកន្លែងឈប់មួយ ដើម្បីទំលាក់ចោល នូវវត្ថុប្រើក្នុងផ្ទះផ្សេងៗ។ រកម៉ោងនៅ *cityoftacoma.org/solidwaste*។

## សំណល់ប្រើក្នុងផ្ទះ ដែលគ្រោះថ្នាក់

ទំលាក់វត្ថុចោល គឺឥតគិតថ្លៃ។ មើលបញ្ជីពេញនៃវត្ថុអាចយកបាន និងគោលការណ៍ណែនាំ នៅ cityoftacoma.org/hazwaste។

### ថ្នាំលាបមានប្រេង



ថ្នាំលាបមានប្រេង គឺអាចងាយឆេះ និងមិនអាចច្នៃប្រើទៀត ឬបាន គ្រវាត់ចោល ក្នុងសំរាមឡើយ។ ថ្នាំលាបមានជាតិឡេតិក ឬទឹក អាចធ្វើអំណោយ ឬសំងួត និង គ្រវាត់ចោល។

### គ្រឿងជូតសំអាតផ្ទះ




គ្រឿងជូតសំអាតផ្ទះខ្លះ អាចបញ្ចេញ ជាតិឧស្ម័នពុល ក្នុងកាលៈទេសៈខ្លះ និងតម្រូវការបោះចោលដោយអ្នក វិជ្ជាជីវៈ។ ហៅ (253) 591-5418 បើសិនអ្នកមិនដឹង ថាអ្នកមានគ្រឿង ជូតសំអាតអ្វីមួយ។ រកគ្រឿងផ្សំនគ្រឿង ជូតសំអាតម្យ៉ាងទៀត ដែលខៀវនៅ *cityoftacoma.org/envirohouse*។

### អំពូលភ្លើងវែង និងបំពង់



អំពូលភ្លើងវែង និងបំពង់ មានចំហាយ ជាតិបារថ និងមិនត្រូវបានបែក ឬ គ្រវាត់ចោល ក្នុងសំរាមឡើយ។

## TACOMA RECYCLE CENTER

ការទំលាក់ចោលវត្ថុអាចច្នៃប្រើទៀត គឺឥតគិតថ្លៃ។ មើលបញ្ជីពេញ នៃវត្ថុអាចយកបាន នៅ tacomarecycles.org។

### សំលៀកបំពាក់



សំលៀកបំពាក់ អាចទំលាក់ ចោល ក្នុងធុងសំលៀកបំពាក់ នៅក្នុង Northwest Center។ សំលៀកបំពាក់ដែលនៅល្អ នឹងបាន ធ្វើអំណោយ ខណៈខោអាវដែលរហែក និងប្រឡាក់ នឹងបានច្នៃប្រើទៀត។

### ម៉ៃក្រូវេវ



គ្រឿងប្រើប្រាស់ក្នុងផ្ទះជាដែក ដែល ពុំមានជាតិគីមី ឬប្រេងអុន ដូចជា ម៉ៃក្រូវេវ និងចង្ក្រាន អាចច្នៃប្រើទៀត នៅក្នុងធុងចោលដែក។

### ប្រអប់ផ្លាស់លំនៅ និងសំភារៈខ្ចប់



ប្រអប់ផ្លាស់លំនៅធំៗ អាចច្នៃប្រើទៀត ក្នុងធុងដាក់ក្រដាសក្រាស់ៗ ។ សំភារៈ ខ្ចប់ ដូចជា ជ័រស្ពើងៗ, ស្តៃរ៉ូហ្វូម និង ប្រដាប់រុំជំៗ អាចច្នៃប្រើទៀត ក្នុងធុង ស្តៃរ៉ូហ្វូម និងជ័រស្ពើងៗ។

## ដឹកសំរាមខ្លួនឯង

ស្វែងយល់អំពីគោលការណ៍ណែនាំ ដឹកសំរាមខ្លួនឯង នៅ *cityoftacoma.org/garbage*។ មើលតម្លៃនៅ cityoftacoma.org/SWMrates។

### ពូក



ទំលាក់ចោលពូករបស់អ្នក ដោយ ឥតគិតថ្លៃ នៅ Tacoma Recovery & Transfer Center ឬអ្នកអាចយក ពូករបស់អ្នក ទៅច្នៃប្រើទៀតជាមួយ NW Furniture Bank ដោយមាន ថ្លៃឈ្នួល។ ស្វែងយល់ថែមទៀត នៅ *cityoftacoma.org/envirohouse*។

### តួម៉ាស៊ីនត្រជាក់



គ្រឿងប្រើប្រាស់ក្នុងផ្ទះ ដូចជាម៉ាស៊ីនត្រជាក់ និងទូទឹកកក មានជាតិប្រេងអុន ដែលអាច លិច និងធ្វើឲ្យគ្រោះថ្នាក់ដល់សុខភាព និង បរិស្ថាន។ របស់ទាំងនេះ ត្រូវតែបានទំលាក់ បោះចោលដោយអ្នកវិជ្ជាជីវៈ នៅ Tacoma Recovery & Transfer Center។

**ឱវាទល្អ** តើធុងច្នៃប្រើទៀតពេញឬ? ទំលាក់ចោលវត្ថុច្នៃប្រើទៀត ដែលសំពីងសំពោង ដូចជាប្រអប់ខ្ចប់ផ្ញើ នៅ Tacoma Recycle Center ពេញមួយឆ្នាំ។

# ធនធានរបស់ SOLID WASTE សំរាប់អ្នកស្រុក

### Solid Waste Management
3510 S. Mullen St.
(253) 502-2100
cityoftacoma.org/solidwaste
solidwaste@cityoftacoma.org

Solid Waste ផ្តល់ជូនសេវាយកសំរាម, វត្ថុច្នៃប្រើទៀត និងម្ហូបចំណី/សំណល់ទីធ្លាព្រមទាំង ជំរើសដឹកខ្លួនឯង សំរាប់សំរាម, វត្ថុច្នៃប្រើទៀត, សំណល់ទីធ្លា និងវត្ថុប្រើក្នុងផ្ទះ ដែលគ្រោះថ្នាក់ នៅ Tacoma Recovery & Transfer Center។

### Call-2-Haul
(253) 573-2468
cityoftacoma.org/call2haul

**គ្រោងពេលមកដឹក នូវវត្ថុសំពីងសំពោង។** វត្ថុធំៗដល់ទៅ 3 និង 15 ប្រអប់ ឬថង់ នៃវត្ថុសំរាមតូចៗ អាចបានប្រមូលដោយ Call-2-Haul។ ថ្លៃឈ្នួលមកដឹក គឺ $75 និងបានបន្ថែមទៅគណនីទឹកភ្លើងរបស់អ្នក។ បើសិនអ្នកពុំមានគណនីទឹកភ្លើងទេ រៀបចំការមកដឹក ជាមួយអ្នកចាត់ចែងភូមិគ្រិះរបស់អ្នក។ ទស្សនាគេហទំព័រ សំរាប់បញ្ជីនៃវត្ថុអាចយកបាន។

### FoodCycling
(253) 502-2100
cityoftacoma.org/foodcycling

FoodCycling គឺជារបៀបមួយ **ដើម្បីបង្វែរសំណល់ម្ហូបអាហាររបស់អ្នក ទៅជាជីអំពុក។** បើសិនអាគាររបស់អ្នក ពុំមានសេវា FoodCycling ទេ ស្នើអ្នកចាត់ចែងភូមិគ្រិះរបស់អ្នក ឲ្យចុះឈ្មោះ!

### Waste Free 253
wastefree253.org

ការផ្លាស់លំនៅ អាចបង្កើតឲ្យមានសំណល់ច្រើន។ **ស្វែងយល់របៀប កាត់បន្ថយសំណល់ និងកន្លែងដើម្បីធ្វើអំណោយ នៃវត្ថុប្រើក្នុងផ្ទះ។**

### Recycle Center
3510 S. Mullen St.
(253) 593-7795
tacomarecycles.org

អ្នកស្រុក**អាចទំលាក់ចោល នូវវត្ថុអាចច្នៃប្រើទៀតទាំងអស់ ដោយឥតគិតថ្លៃ** រួមទាំងអ្វីៗដែលមិនអាចយក នៅចិញ្ចើមថ្នល់ (ថង់ជ័រ និងប្រដាប់រុំ, ប្រអប់ស្នូកលៀស, ស្ទ្រូហ្វូម, ខ្សែអគ្គិសនី, ល.) នៅឯ Recycle Center។ Recycle Center គឺបើកប្រាំពីរថ្ងៃមួយអាទិត្យ ម៉ោង 8 ព្រឹក–6 ល្ងាច។ ទស្សនាគេហទំព័រ សំរាប់សេចក្តីពិស្តារថែមទៀត។

### Household Hazardous Waste
3510 S. Mullen St.
(253) 591-5418
cityoftacoma.org/hazwaste

អ្នកស្រុក **អាចចោល សំណល់ប្រើក្នុងផ្ទះដែលគ្រោះថ្នាក់** (ថ្មពិល, អំពូលភ្លើង, គ្រឿងជូតសំអាតផ្ទះ, ល.) **ដោយឥតគិតថ្លៃ** នៅឯ Household Hazardous Waste Center។ ទស្សនាគេហទំព័រ សំរាប់បញ្ជីនៃវត្ថុអាចយកបាន។

### EnviroHouse
ការិយាល័យ៖ (253) 573-2426
ចល័ត៖ (253) 341-2331
ehouse@cityoftacoma.org
cityoftacoma.org/envirohouse

**សិក្ខាពិភាក្សាតាមបណ្តាញ ឥតគិតថ្លៃ ស្តីពីការធ្វើច្បារ, ការសំអាត, និងការរស់នៅ អាចរក្សាបាន** ពេញមួយឆ្នាំ នៅឯ EnviroHouse—ការបង្ហាញផ្ទះគំរូមួយ នៃអាគារខៀវ និងគំនិតទេស្សភាពធម្មជាតិ, សំភារៈ, និងបច្ចេកទេស ដើម្បីបង្កើតផ្ទះ និងពិភព មួយមានសុខភាពល្អ។ ចូលរួមសិក្ខាពិភាក្សា រស់រវើកតាមភាពជាក់ស្តែង ឬមើលការថតពីមុនៗ នៅឯគេហទំព័រ។

**តើអ្នកបានដឹងឬទេ?**

អ្នកអាចហៅ 3-1-1 ដើម្បីនិយាយជាមួយអ្នកណាម្នាក់ ជាភាសាខ្មែរ អំពីសេវារបស់ក្រុង Tacoma។